**អង្គរបុរី**

**សម្លេងខ្មែរនៅបរទេស**

# ការទិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ ពុទ្ធភាសិតមួយបទពោលថា បុគ្គលណាប្រទូស្តរាយបៀតបៀនដល់អ្នកដែលមិនប្រទូស្តរាយជាអ្នកបរិសុទ្ធ មិនមានកិលេសគ្រឿងកង្វល់ បានរមែងត្រឡប់មករកបុគ្គលពាលនោះវិញ ។

website : www.hoksavann.org

ថ្ងៃទី១៨ ឧសភា ២០០៧



ប្រធានបទខាងលើនេះ ជាពុទ្ធភាសិតនៅក្នុងធម្មបទនៃគម្ពីរព្រះពុទ្ធសាសនាដែលជាគាថាថា យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ សុទ្ធស្ស បោសស្ស អនង្គណាស្ស តមេវ ពាលំ បច្ចេតិ បាបំ សុខុមោ រជោ បដិវាតំ វខិត្តោ ប្រែថា បុគ្គលណាប្រទូស្តរាយបៀតបៀនដល់អ្នកមិនប្រទូស្តរាយ ជាបុគ្គលបរិសុទ្ធ មិនមានកិលេសគ្រឿងកង្វល់ បានរមែងត្រឡប់មករកបុគ្គលនោះវិញ ដូចជាផង់ធូលីដ៏ល្អិត ដែលគេបាចប្រាសខ្យល់ រមែងរសាត់មករកអ្នកបាចវិញយ៉ាងនេះឯង ។ គាថានេះ ព្រះបរមសាស្តាប្រារព្ធចំពោះព្រានសុនខម្នាក់ឈ្មោះកោក: ។ រឿងដោយសង្ខេបថា ថ្ងៃមួយមានព្រានម្នាក់ឈ្មោះកោក:បានបណ្តើរហ្វូងឆ្កែទៅដេញចាប់សត្វក្នុងព្រៃ គាប់ជួនថ្ងៃនោះរកសត្វពុំបានសោះ ព្រានដើរចុះដើរឡើង ស្រាប់តែជួបព្រះថេរ:មួយអង្គទើបគិតថា អញរកសត្វពុំបានថ្ងៃនេះ ព្រោះតែបានជួបនឹងមនុស្សអាក្រក់កាឡកិណីនេះឯង ក៏កើតកំហឹងពន្យុះឆ្កែឲ្យដេញខាំ ព្រះថេរ:រត់ឡើងដើមឈើដើម្បីគេចពីឆ្កែ ព្រានព្រៃឃើញហើយក៏ស្ទុះទៅចាក់ព្រះបាទលោកដោយលំពែង ទោះបីលោកអង្វរថា ញោមកុំធ្វើដូច្នេះ អាត្មាគ្មានកំហុសអ្វីទេ ព្រានរឹតតែចាក់ថែមលើសពីមុនទៀត ។ ពេលនោះ ស្រាប់តែចីវររបស់ព្រះថេរ:បានរបូតធ្លាក់ មកគ្របលើខ្លួនព្រានព្រៃ ។ បាបកម្មបានផ្តល់ដល់ជនពាល ហ្វូងឆ្កែឃើញចីវរធ្លាក់គ្របលើម្ចាស់ស្មានខុសថា ព្រះថេរ:ធ្លាក់ពីលើដើមឈើ

ហើយក៏នាំគ្នាបោលស្ទុះចូលទៅខាំក្រញ៉ីម្ចាស់ខ្លួនឯងស្លាប់ក្នុងពេលនោះទៅ ។ ព្រះថេរៈបានចុះពីលើដើមឈើ កើតមានសេចក្ដីសង្ស័យអំពីសីលរបស់ខ្លួន ដោយព្រាននេះស្លាប់ដោយសារចីវររបស់លោកទើបចូលទៅក្រាបបង្គំទូលសួរព្រះពុទ្ធជាម្ចាស់ព្រះអង្គត្រាស់ថាសីលរបស់អ្នកមិនដាច់ទេ ទើបព្រះអង្គត្រាស់នូវគាថាដូចពោលមកហើយ ។ ក្នុងគាថានេះមានពាក្យថា អ្នកបរិសុទ្ធ គឺអ្នកពុំធ្វើអំពើបាប អ្នកពុំបៀតបៀនអ្នកដទៃ ។ បុគ្គលណាប្រទូស្តរាយចំពោះបុគ្គលបរិសុទ្ធបែបនេះ បាបរមែងធ្លាក់មកលើបុគ្គលនោះវិញ ដូចជាព្រានព្រៃឈ្មោះកោកៈ ដែលត្រូវឆ្កែរបស់ខ្លួនខាំស្លាប់ ព្រោះបានបៀតបៀនព្រះថេរៈ ដែលជាបុគ្គលបរិសុទ្ធ ជាបុគ្គលឥតទោសយ៉ាងនេះឯង ។ ប្រៀបដូចផង់ធូលីដែលគេបាចច្រាសខ្យល់ ផង់ធូលីនោះរមែងវិលត្រឡប់មករកអ្នកបាចវិញ ស្របនឹងពាក្យខ្មែរមួយបទទៀតពោលថា បាចអង្កាមច្រាសខ្យល់ អង្កាមនោះរមែងត្រឡប់មករកអ្នកបាចវិញ ។ ស្របនឹងពុទ្ធភាសិតមួយបទពោលថា បាតដៃបើគ្មានដំបៅទេ ទោះបីបុគ្គលយកថ្នាំពិសមកដាក់ ក៏ថ្នាំពិសនោះពុំអាចចូលជ្រាបក្នុងសាច់ ធ្វើឲ្យបុគ្គលឈឺចាប់បានឡើយ ។

ពុទ្ធភាសិតដូចពោលមកនេះ ជាពាក្យប្រៀបប្រដៅរបស់ព្រះពុទ្ធ គួរយកមករំលឹកដល់ខ្មែរណា ដែលបានប្រព្រឹត្តអំពើហឹង្សាបៀតបៀនលើខ្មែរស្លូតត្រង់ គប្បីឈប់ប្រព្រឹត្តចាប់ពីពេលនេះទៅ ព្រោះអំពើដែលខ្លួនប្រព្រឹត្តនោះ នឹងផ្ដល់សេចក្ដីទុក្ខមកខ្លួនវិញពុំខានឡើយ ។

ពលរដ្ឋខ្មែរបានឆ្លងកាត់សេចក្ដីទុក្ខវេទនាជាយូរមកហើយ ដោយសារតែអំពើហឹង្សាមិនគោរពតាមពាក្យព្រះពុទ្ធនេះ គួរកុំកើតមានតទៅទៀត ។ ទំនាស់ក្នុងគ្រួសារក្នុងសហគម និងក្នុងបញ្ហាជាតិត្រូវតែនាំគ្នាដោះស្រាយដោយសន្តិវិធីឆ្លងតាមការនិយាយគ្នា កុំប្រើកម្លាំងបាយ កម្លាំងអាវុធ តាមលក្ខណៈពាលឡើយ ។ អ្នកនយោបាយកុំលួចសម្លាប់គ្នា បើពេលនេះគេរកមុខមិនឃើញ ពេលក្រោយគេមុខតែរកឃើញ ។ អ្នកស៊ីឈ្នួលសម្លាប់ក៏ត្រូវតែឈប់ ព្រោះជាមុខរបរអមនុស្សធម៌ នឹងផ្ដល់ទុក្ខឲ្យខ្លួនវិញ ត្រូវតែងាកទៅរកមុខរបរសុចរិតវិញ ។ ក៏ដូចជាចោរលួចចោរប្លន់ជាមុខរបរទុច្ចរិតត្រូវមានទោសតាំងផ្លូវលោកនិងផ្លូវធម៌ ក៏ត្រូវវៀរចាកឲ្យស្រឡះ ។ មុខរបរជួញដូរមនុស្ស មានជួញដូរស្ត្រីឲ្យធ្វើជាស្ត្រីពេស្យាជាដើម ដែលពិភពលោកផ្ដន្ទាទោសនិងព្រះពុទ្ធក៏ហាម បើខ្មែរណាប្រព្រឹត្តគប្បីឈប់ចាប់ពីថ្ងៃនេះទៅ ។ អ្នកមានអំណាចខ្មែរណាដែលរំលោភយកដីរដ្ឋនិងដីរបស់ប្រជាពលរដ្ឋ ត្រូវតែមានការខ្មាស់អៀន ហើយប្រគល់ឲ្យរដ្ឋនិងឲ្យប្រជាពលរដ្ឋវិញ ។ ត្រូវជៀសវាងការច្រណែនឈ្នានិសគ្នា រហូតដល់ប្រើអំពើហឹង្សាដូចជាការលួចបាញ់សម្លាប់សិល្បការិនី នេះជាអំពើថោកទាបព្រៃផ្សៃណាស់ ដែលពិភពលោកមិនដែលកើតមាន ។ តុលាការខ្មែរល្មមខ្មាស់សម្បជញ្ញៈរបស់ខ្លួនហើយ មិនគួរយកចំណេះវិជ្ជារបស់ខ្លួនមកប្រព្រឹត្តទុច្ចរិត គឺកាត់សេចក្ដីដោយអយុត្តិធម៌ដោយសារខ្លាចអ្នកមានអំណាច ដោយសារ

បក្សពួក ដោយសារដុល្លារឡើយ ។ អំពើបាបកម្មដែលអ្នកបានប្រព្រឹត្តមកលើអ្នកស្លូតត្រង់ អ្នកនឹងត្រូវទទួលអំពើបាបកម្មនោះវិញ ដូចពុទ្ធភាសិតដែលបានពោលមកហើយ ។៚

❄ ❄

❄